# ព្រះរាជក្រឹត្យ

នស/រកត/០១១៨/០០៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

  បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីវិសោធនកម្មមាត្រា ៤,១០ និង ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៩០០/១៦០ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១**: បញ្ចប់តំណែង ៖

១- ឯកឧត្តម **ប្រាក់ សុខឃុំ** ពីអគ្គលេខាធិការរងប្រចាំការ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន មានឋានៈស្មើ រដ្ឋមន្ត្រី

២- ឯកឧត្តម **ឡុច តារា** ពីអគ្គលេខាធិការរង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា២**: តែងតាំង និងផ្តល់ឋានៈ ៖

១- ឯកឧត្តម **ប្រាក់ សុខឃុំ** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋមន្ត្រី ។

២- ឯកឧត្តម **ឡុច តារា** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា៣**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៨

ពកស.១៨០១.០០៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ០៣ ស.ណ

**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**

ថ្ងៃអង្គារ ៣រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មករា ឆ្នាំ២០១៨

**ឋ. អគ្គលេខាធិការរាជរដ្ឋាភិបាល**
**អគ្គលេខាធិការរង**

**ជាង អេងឌូន**